ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប
សាលក្រមរដ្ឋប្បវេណី
-លេខ ២២ "ឈ" /២៤៣
-ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១
-សំណុំរឿងរដ្ឋប្បវេណីលេខ ៥០០
ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ៩ និង ០០ នាទី ព្រឹក នៅសាលសវនាការទី១ លើសំណុំរឿង រដ្ឋប្បវេណីលេខ ៥០០ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយមានសមាសភាព ៖

### ចៅក្រមជំនុំជម្រះ

-លោក [redacted] ជាចៅក្រមនៃសាលាដំបូងខេត្តសៀមរាប។

### ក្រឡាបញ្ជី

-លោក [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តសៀមរាប។

- ដើមចោទ៖ ឈ្មោះ [redacted] វ៉ាន់ដា ភេទស្រី ជនជាតិខ្មែរ
ទីលំនៅបច្ចុប្បន្នភូមិ[redacted]។
អ្នកតំណាងដោយអាណត្តិលោក[redacted]អាសយដ្ឋានផ្ទះលេខ[redacted] ។
- ចុងចម្លើយ៖ ឈ្មោះ[redacted]សេងអឿន ភេទស្រី កើតឆ្នាំ១៩៨៩ ជនជាតិខ្មែរ ។
មានទីលំនៅបច្ចុប្បន្ន[redacted]

## I. អង្គហេតុ និងចំណុចវិវាទ

**១.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ÷**

ក. ឲ្យចុងចម្លើយឈ្មោះ [redacted] សេងអឿន សងប្រាក់មកឲ្យដើមចោទឈ្មោះ [redacted] វ៉ាន់ដា នូវប្រាក់ដើមចំនួន ៥.០០០ $ (ប្រាំពាន់ដុល្លាអាមេរិក)និងការប្រាក់ចំនួន១.៥%ភាគរយ ក្នុងមួយខែគិតចាប់ពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទូទាត់ប្រាក់អស់គ្រប់ចំនួន និងប្រាក់ពិន័យ១% នៃប្រាក់ដើមគិតចាប់ពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទូទាត់ប្រាក់អស់គ្រប់ចំនួន និងទាមទារជំងឺចិត្ត និងសេវាផ្សេងៗចំនួន ៥.០០០$ (ប្រាំពាន់ដុល្លាអាមេរិក) ។

ខ. សូមឲ្យតុលាការប្រកាសអនុវត្តបណ្តោះអាសន្នគ្រង់ប្រាក់ដើមចំនួន ៥.០០០$ (ប្រាំពាន់ដុល្លាអាមេរិក) ។

គ. ឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

២.**ការពន្យល់ត្រួសៗអំពីរឿងក្តី ÷**

ចុងចម្លើយឈ្មោះ [redacted] សេងអឿន បានស្នើសុំខ្ចីប្រាក់ពីឈ្មោះ [redacted] វ៉ាន់ដា ចំនួន ៥.០០០ $ (ប្រាំពាន់ដុល្លារអាមេរិក) ដោយគិតការប្រាក់ចំនួន ៥% ក្នុងមួយខែ ដូចមានក្នុងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩។ ដើម្បីធានាកម្ចីនេះ ចុងចម្លើយបានយល់ព្រមដាក់ហ៊ីប៉ូតែកទ្រព្យ (លិខិតបញ្ជាក់ការកាន់កាប់ និងប្រើប្រាស់ដីធ្លី លេខ ៣៣/០៨ ក.ព.ឃ ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ២០០៨ ដែលមានទីតាំងភូមិតាច្រនៀង ឃុំកំពង់ឃ្លាំង ស្រុកសូត្រនិគម ខេត្តសៀមរាប ។ សព្វថ្ងៃនេះ ចុងចម្លើយបានរំលោភបំពានលើកិច្ចសន្យាខ្ចីប្រាក់ ដោយពុំបានបង់ប្រាក់ជាច្រើនខែមកហើយ ហើយក៏មិនបានសងប្រាក់ដើមមកវិញដូចមានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់ដែរកំណត់ពេលត្រឹមតែ៣ខែប៉ុណ្ណោះ ។

៣.**អង្គហេតុដែលគ្មានចំណុចវិវាទ ÷**

ចុងចម្លើយឈ្មោះ [redacted] សេងអឿន ភេទស្រី អាយុ ៣២ឆ្នាំ ខ្លួនទទួលស្គាល់ប្រាក់ដើមចំនួន ៥.០០០$ (ប្រាំពាន់ដុល្លាអាមេរិក) និងការប្រាក់១.៥% ដូចការទាមទាររបស់ដើមចោទ។ ខ្លួនបានសងការប្រាក់ចំនួន២៥០$ (ពីររយហាសិបដុល្លាអាមេរិក) ក្នុងមួយខែសរុបចំនួន ៧៥០$ (ប្រាំពីររយហាសិបដុល្លាអាមេរិក) ឲ្យទៅដើមចោទ ។ ដើមចោទបានស្នើរសុំទាមទារ ការប្រាក់តាមកំណត់ច្បាប់ត្រឹមតែ ១.៥% ក្នុង ១ខែ ឬ ១៨% ក្នុង ១ឆ្នាំ វិញ តែចំពោះប្រាក់ពិន័យ និងសំណងជម្ងឺចិត្តនៅទាមទារដដែល ។

៤.**ចំណុចវិវាទ÷**

១. តើដើមចោទមានសិទ្ធិទាមទារប្រាក់ពិន័យ ១% ក្នុងមួយខែ គិតចាប់ពីថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទូទាត់ប្រាក់អស់គ្រប់ចំនួន ដែរឬទេ ?

២. តើដើមចោទមានសិទ្ធិទាមទារជម្ងឺចិត្ត និងសេវាផ្សេងៗចំនួន ៥.០០០$ ដែរឬទេ?

៥.**ការអះអាងរបស់គាគីស្តីពីចំណុចវិវាទ÷**

**អះអាងដោយអ្នកតំណាងដោយអាណត្តិរបស់ដើមចោទលោក [redacted] សៅលី៖** ខ្លួនសុំទាមទារប្រាក់ពិន័យ ១% ក្នុងមួយខែ គិតចាប់ពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទូទាត់ប្រាក់អស់គ្រប់ចំនួន និងជម្ងឺចិត្តនិងសេវាផ្សេងៗចំនួន ៥.០០០$ ដោយផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩ ។

**ការអះអាងដោយចុងចម្លើយឈ្មោះ [redacted] សេងអឿន** ៖ ខ្លួនមិនទទួលស្គាល់តាមការទាមទាររបស់ដើមចោទនោះទេ ព្រោះថាខ្លួនពុំមានលទ្ធភាពរកប្រាក់សងដើមចោទនោះទេ។ ខ្លួនសុំសងតែប្រាក់ដើមនិងការប្រាក់ ១.៥% ក្នុង ១ខែ ។

## សំអាងហេតុ

### ១. ស្តីពីចំណុចវិវាទទី១ ទី២

ផ្អែកភស្តុតាង តុលាការទទួលស្គាល់ថា ចុងចម្លើយពិតជាបានជំពាក់ប្រាក់ដើមចោទឈ្មោះ [redacted] វ៉ាន់ដា ចំនួន ៥.០០០$ (ប្រាំពាន់ដុល្លាអាមេរិក) ពិតប្រាកដមែន ហើយចុងចម្លើយបានសងការប្រាក់ចំនួន២៥០$ (ពីររយហាសិបដុល្លាអាមេរិក) ក្នុងមួយខែ សរុបចំនួន ៧៥០$ (ប្រាំពីររយហាសិបដុល្លាអាមេរិក) ដោយផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៩ ។ ចំពោះការទាមទាររបស់ដើមចោទនូវប្រាក់ពិន័យ១% ក្នុងមួយខែ គិតចាប់ពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទូទាត់ប្រាក់អស់គ្រប់ចំនួន តុលាការយល់ឃើញថា ចុងចម្លើយ បានបង់ប្រាក់ការសរុបចំនួន៧៥០$ (ប្រាំពីររយហាសិបដុល្លាអាមេរិក) ឲ្យទៅដើមចោទរួចទៅហើយ ប្រាក់នេះចាត់ទុកថា

ជាប្រាក់ពិន័យ១% ដែលដើមចោទទាមទារពីចុងចម្លើយ ម៉្យាងវិញទៀត ដើមចោទជាបុគ្គលឯកជន មិនមែនជានីតិបុគ្គល ឬ ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬ ជាធនាគារដែលតម្រូវឱ្យមានការទាមទារបន្ថែមនូវប្រាក់ពិន័យយឺតយ៉ាវនៃការបង់ប្រាក់ឡើយ ត្រង់ចំណុចនេះ តុលាការមិនសម្រេចតាមការទាមទាររបស់ដើមចោទទេ។

២. ចំពោះការទាមទារ ជម្ងឺចិត្តនិងសេវាផ្សេងៗចំនួន ៥.០០០$ (ប្រាំពាន់) ដុល្លារអាមេរិក ពីចុងចម្លើយ តុលាការ យល់ឃើញថា ការទាមទារនេះ ពុំមានលក្ខណៈត្រឹមត្រូវឡើយ ដោយហេតុថា តុលាការបានសម្រេច អំពីការប្រាក់ទៅឱ្យដើមចោទរួចហើយ គប្បីច្រានចោលការទាមទារត្រង់ចំនុចនេះ។

៣. **ស្ដីពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី**

ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ផ្អែកតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៤. **ស្ដីពីការប្រកាសអនុវត្តបណ្ដោះអាសន្ន**

ដើមចោទបានសុំ ទាមទារសុំអនុវត្តជាបណ្ដោះអាសន្ន ត្រង់ចំណុចទី១ លើប្រាក់ដើមចំនួន ៥.០០០$ (ប្រាំពាន់ដុល្លារអាមេរិក) តុលាការយល់ឃើញថា ចុងចម្លើយបានទទួលស្គាល់ការទារលើប្រាក់ដើមនេះរួចហើយ ហេតុដូច្នេះ មានភាពចាំបាច់ដើម្បីធ្វើការ ប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នបានតាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្ដីសម្រេចបញ្ចប់

១- បង្គាប់ឱ្យចុងចម្លើយៈ ឈ្មោះ [redacted] សេងរឿន ភេទស្រី កើតឆ្នាំ ១៩៨៩ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ភូមិផ្សារឃ្លាំង ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប សងប្រាក់ឱ្យដើមចោទឈ្មោះ [redacted] វ៉ាន់ដា នូវៈ

ក/ ប្រាក់ដើមចំនួន ៥.០០០ $ (ប្រាំពាន់ដុល្លារអាមេរិក) ។

ខ/ ការប្រាក់ចំនួន១.៥%ភាគរយ ក្នុងមួយខែ គិតចាប់ពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទូទាត់ប្រាក់អស់គ្រប់ចំនួន។

២/ ច្រានចោលការទាមទារផ្សេងទៀតរបស់ដើមចោទ តាមពាក្យបណ្ដឹងចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០។

៣/ សាលក្រមនេះ ប្រកាសឱ្យអាចអនុវត្តជាបណ្ដោះអាសន្នបាន ត្រង់សេចក្ដីសម្រេចចំនុចទី១.ក ។

៤/ ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ ទុកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ចៅក្រម**

ហត្ថលេខា និង ត្រា[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៤កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ពស២៥៦៥

សៀមរាប, ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០២១

បានឃើញ

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner